វេទិកាពលរដ្ឋ
PEOPLE FORUM
ពលរដ្ឋខ្លាំង ជាតិខ្លាំង
STRONG PEOPLE STRONG NATION

វ.ព.រ.
PFOR

សហរដ្ឋអាមេរិក ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២២

# សេចក្ដីថ្លែងការណ៍
## ការបោះឆ្នោត ៥មិថុនា២០២២ ជាឧក្រិដ្ឋកម្មប្រជាធិបតេយ្យ

**វេទិកាពលរដ្ឋ** មានការសោកស្ដាយយ៉ាងខ្លាំង ដែលគណបក្សនានាចូលរួមបោះឆ្នោត ដោយមិនបានបង្ហាញសេចក្ដីក្លាហានតវ៉ាជាសាធារណៈ ទាមទារឲ្យមានការកែទម្រង់ដំណើរការនៃការបោះឆ្នោតជាមុន ពិតមែនតែការចូលរួមនៅក្នុងការបោះឆ្នោតខាងមុខ គឺជាសិទ្ធិ សេរីភាព ការជ្រើសរើស និង ការសម្រេចចិត្តរបស់ **គណបក្សនយោបាយ។ គណបក្សទាំងឡាយ** សមណាស់តែមានសេចក្ដីក្លាហាន ក្នុងសកម្មភាពនយោបាយរបស់ខ្លួន ឲ្យស័ក្តិសមជាអង្គការ នៃអ្នកនយោបាយបម្រើពលរដ្ឋ នៅក្នុងចលនាតស៊ូនយោបាយ ដើម្បីលទ្ធិប្រជាធិបតេយ្យ។

ការបោះឆ្នោតឃុំសង្កាត់ ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ គឺជាព្រឹត្តិការណ៍ ដែល **គណបក្សប្រជាជនកម្ពុជា** ចាត់ចែងទាំងស្រុង ដើម្បីប្លន់យកអំណាចនៅមូលដ្ឋាន ដោយទាញគណបក្សផ្សេងៗទៀតឲ្យចូលរួមកំដរ ឲ្យឃើញមានរូបភាពបោះឆ្នោតគគ្រឹកគគ្រេង។ រូបភាពគគ្រឹកគគ្រេងទាំងនោះ មិនខុសអ្វីពីធ្វើសកម្មភាពបោកបញ្ឆោតសកម្មជន អ្នកគាំទ្រ និង ប្រជាពលរដ្ឋម្ចាស់ឆ្នោត ឲ្យ**គណបក្សប្រជាជនកម្ពុជា** យកទៅប្រើប្រាស់ ដើម្បីបិទបាំងមុខមាត់ខុសច្បាប់ នៃរដ្ឋាភិបាលបច្ចុប្បន្នរបស់លោក **ហ៊ុន សែន** ដូចដែលលោក **ហ៊ុន សែន** ប្រកាសនៅទីក្រុងដាវ៉ូស ប្រទេសស្វីស យប់ថ្ងៃទី២១ ឧសភា បំភ័ន្តយកចំណេញមុខ សម្រាប់គណបក្សខ្លួនរួចទៅហើយថា *យុទ្ធនាការបោះឆ្នោត «ដែលត្រូវធ្វើឡើង ១៧គណបក្សចូលរួម នោះហើយជាទិដ្ឋភាពនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស»*។

**វេទិកាពលរដ្ឋ** មើលឃើញថា **គណបក្សប្រជាជនកម្ពុជា** និង លោក **ហ៊ុន សែន** ត្រូវការតែរូបភាពឃោសនា និងវត្តមានប្រជាពលរដ្ឋចូលរួមបោះឆ្នោត ដើម្បីបំភ្លៃប្រាប់សហគមន៍អន្តរជាតិ អំពីរបស់ដែលហៅថា សេរីភាពប្រជាធិបតេយ្យ។ ប៉ុន្តែលទ្ធផលបោះឆ្នោត ត្រូវលោក **ហ៊ុន សែន** និង **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**(គ.ជ.ប.) កំណត់ទុកជាមុនរួចទៅហើយ។ **វាជាការបោះឆ្នោតដ៏អាក្រក់បំផុត ដែលសហគមន៍អន្តរជាតិ និង អង្គការជំនាញបោះឆ្នោតនៅក្នុងកម្ពុជា មិនដាក់អ្នកសង្កេតការណ៍តាមដាន ដើម្បីធ្វើរបាយការណ៍វាយតម្លៃទេ។**

**គណបក្សប្រជាជនកម្ពុជា** និង **គ.ជ.ប.** អាចបែងចែកអាសនៈខ្លះៗ ឲ្យគណបក្សចូលរួមមួយចំនួន ដើម្បីគ្រាន់តែឲ្យមើលឃើញរូបភាពសម្លេងចម្រុះ លម្អអំណាចរដ្ឋបាលរបស់លោក **ហ៊ុន សែន** ក្នុងគោលដៅលួងលោមភ្នែកប្រជាពលរដ្ឋ និង សហគមន៍អន្តរជាតិសេរីប្រជាធិបតេយ្យ។ *ប៉ុន្តែ តំណែងមេឃុំ និង ចៅសង្កាត់ នៅទូទាំងប្រទេស អាចនឹងត្រូវគណបក្សប្រជាជនកម្ពុជា រៀបចំទិន្នន័យបន្លំយកស្ទើរតែទាំងអស់* ។

Address: 58 Poplar Street, Plains PA 18 705, USA

***ការបោះឆ្នោតឃុំសង្កាត់ខាងមុខនេះ*** មិនមែនត្រឹមតែជាការលួចសន្លឹកឆ្នោតទេ ប៉ុន្តែ ***គឺជាឧក្រិដ្ឋកម្មប្លន់លទ្ធផលនៃការបោះឆ្នោតតែម្តង*** ។ បើជាការលួចសន្លឹកឆ្នោត ដូចការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១៧ និង ការបោះឆ្នោតជាតិឆ្នាំ២០១៣ គណបក្សក្រៅរដ្ឋាភិបាល ក៏អាចប្រមូលបានអាសនៈប្រជំប្រសងនឹងគណបក្សកាន់អំណាចដែរ ពីព្រោះ គណបក្សកាន់អំណាច និង **គ.ជ.ប.** បានប្រឹងលួច តែនៅចន្លោះប្រហោង ដែលអាចលួចបានតែប៉ុណ្ណោះ។ ***ប៉ុន្តែ បើជាករណីប្លន់ ដូចការបោះឆ្នោតជាតិឆ្នាំ២០១៨ និង ឃុំសង្កាត់ឆ្នាំ២០២២ នោះលទ្ធផលនឹងចេញតួលេខ ស្រេចតែគណបក្សកាន់អំណាចកំណត់ចង់បាន*** ។

**វេទិកាពលរដ្ឋ** ពុំមានជំហរប្រឆាំងនឹងការសម្រេចចិត្តរបស់ប្រជាពលរដ្ឋម្ចាស់ឆ្នោត ឬ គណបក្សនយោបាយណាឡើយ ប៉ុន្តែ ***ប្រឆាំងដាច់ខាតនឹងអំពើអយុត្តិធម៌ធ្ងន់ធ្ងរ និងឧក្រិដ្ឋកម្មបោះឆ្នោត***។ យើងខ្ញុំយល់ឃើញថា ទោះបីជាប្រជាពលរដ្ឋគ្រប់រូប ចេញទៅបោះឆ្នោតឲ្យគណបក្សក្រៅរដ្ឋាភិបាល នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ ក៏ដោយ ក៏នឹងមិនធ្វើឲ្យមានការប្រែប្រួលអ្វីដែរ ពីព្រោះ លទ្ធផលបោះឆ្នោត ត្រូវ**គណបក្សប្រជាជនកម្ពុជា** និង **គ.ជ.ប.** រៀបចំទុករួចស្រេច តាំងពីមុនការបោះឆ្នោតម្ល៉េះ។

**ប្រធាន វេទិកាពលរដ្ឋ**

**គឹម សុខ**